# សុន្ទរកថាចំណាប់អារម្មណ៍របស់ លោក ឈិត សំអាត

# នាយកប្រតិបត្តិ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា

# ទិវាអន្តរជាតិនារី ៨មីនា លើកទី ៩៧ ឆ្នាំ ២០០៧

## ស្រុកបារាយណ៍ ខេត្តកំពង់ធំ

ខ្ញុំបាទ សូមថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ

សូមគោរព ឯកឧត្តម **ណាំ ទុំ** អភិបាលខេត្តកំពង់ធំ

លោក **សុខ ឈៀង** អភិបាលស្រុកបារាយណ៍

លោកស្រី **ទូច ស៊ីថុល** ប្រធានមន្ទីរកិច្ចការនារីខេត្តកំពង់ធំ

លោក/លោកស្រីតំណាងអង្គការមិនមែនរដ្ឋាភិបាលនានា និង សមាជិកបណ្តាញវេទិកាយេនឌ័រជាទីរាប់អាន

លោក/អ្នកគ្រូ ប្អូនៗ សិស្សានុសិស្ស លោកអ៊ំ ពូ មីង បងប្អូនទាំងអស់ជាទីស្នេហា

តាងនាមអោយអង្គការ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា ថ្ងៃនេះខ្ញុំបាទមានកត្តិយស និងមានសេចក្តីរីករាយ សូមថ្លែងអំណរគុណ និងស្វាគមន៍យ៉ាងកក់ក្តៅចំពោះវត្តមានរបស់ ឯកឧត្តម លោក/លោកស្រី ដែលអញ្ជើញ មកពី ស្ថាប័នជុំវិញ ខេត្ត ស្រុក អង្គការនានា ក្រុមប្រឹក្សាឃុំ និងសហគមន៍ ចូលរួម ប្រារព្ធទិវាអន្តរជាតិនារី ៨មីនា លើក ទី ៩៧ ឆ្នាំ២០០៧ នៅក្នុងទីរួម ស្រុកបារាយណ៍ ខេត្តកំពង់ធំនេះ។

ឆ្លៀតឱកាសនេះខ្ញុំបាទសូមជំរាបថា វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា គឺ ជាអង្គការសមាជិកភាព ដែលមាន អង្គការជាតិ និងអន្តរជាតិ នៅកម្ពុជាចូលរួមទាំងអស់ចំនួន ៨៣ អង្គការ។ យើងធ្វើការផ្តោតទៅលើការចែកចាយនូវព័ត៌មាន ពិភាក្សាដេញដោល និងធ្វើការតស៊ូមតិទៅលើបញ្ហាជាអទិភាពនានាដែលប៉ះពាល់ទៅដល់ការអភិវឌ្ឍន៍ នៅប្រទេសកម្ពុជាដូចជា បញ្ហាយេនឌ័រ គោលនយោបាយអភិវឌ្ឍន៍ សេដ្ឋកិច្ចនិងពាណិជ្ជកម្ម បរិស្ថាន ដីធ្លី ការរុះរើតាំងទីលំនៅ សិទ្ធិស្របច្បាប់នៃជនជាតិ ដើមភាគតិច និង ព្រៃឈើ ។ល។ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា តាមរយៈបណ្តាញវេទិកាយេនឌ័របានធ្វើការដើម្បី ធានាឱ្យមានការបញ្ជ្រាបយេនឌ័រនៅក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ជាពិសេសធានាឱ្យនារីទទួលបានផលស្មើរគ្នា និងត្រូវបានគេ យកចិត្តទុកដាក់ និងមានសំលេងក្នុងការរៀបចំ និងអនុវត្តគោល នយោបាយនានារបស់រដ្ឋាភិបាល។

ជារៀងរាល់ឆ្នាំ វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា តែងតែសហការជាមួយក្រសួង/មន្ទីរកិច្ចការនារី រៀបចំពិធី នេះឡើង ដើម្បីអបអរសាទរទិវាប្រវត្តិសាស្ត្រសិទ្ធិនារីអន្តរជាតិ និង ដើម្បីរំលឹកឡើងវិញនូវមហាសាមគ្គីភាព ជាព្រលឹង និងជានិម្មិត រូបនៃស្មារតីតស៊ូ និងវិរៈភាពរបស់កម្មការិនី ទូទាំងសកលលោកដែលបានខំប្រឹងប្រែងយ៉ាងអស់ពី សមត្ថភាពដើម្បីរំដោះនារីដោយ ទាមទារអោយមានការអនុវត្តសិទ្ធិស្មើគ្នារវាងបុរសនិងស្ត្រី។ នេះគឺជាខួបលើកទី ៩៧ ដែលគេបានប្រារព្ធឡើងនៅក្នុងប្រទេសជា ច្រើន លើ សកលលោក។ ថ្ងៃនេះក៏ជាទិវាដ៏ឧត្តុងឧត្តម ដែលវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល និង អង្គការជាសមាជិកភាពនៃ បណ្តាញវេទិកាយេនឌ័រ បានសហការជាមួយមន្ទីរកិច្ចការនារីខេត្តកំពង់ធំ រៀបចំទិវាអន្តរជាតិនារី ៨មីនា នេះឡើងក្រោមប្រធានបទ **"គាំទ្រស្ត្រីជាអ្នកដឹកនាំ ធានាសន្តិសុខស្បៀង"** ក្នុងគោលបំនង លើកកំពស់ការយល់ដឹងលើបញ្ហាយេនឌ័រពាក់ពន្ធ័ការអភិវឌ្ឍសេដ្ឋ កិច្ច និង ផ្សព្វផ្សាយជំរុញអោយស្ត្រីយល់ដឹងពីសិទ្ធិ និងតួនាទីជាអ្នកដឹកនាំក្នុងសង្គម និង ការធ្វើសេចក្តីសំរេចចិត្ត។

*ឯកឧត្តម លោក លោកស្រី ប្អូនៗ សិស្សានុសិស្ស លោកអ៊ី ពូ មីង បងប្អូនទាំងអស់*

យើងដឹងហើយថានារី និងបុរសមានសិទ្ធិស្មើគ្នាក្នុងការធ្វើសេចក្តីសំរេចចិត្ត ធ្វើនយោបាយ និងចូលរួមការងារផ្សេងៗក្នុងសង្គម ដោយបានកំរៃស្មើគ្នានឹងបុរសនៅក្នុងការងារប្រហាក់ប្រហែលគ្នា ដោយគ្មានការរើសអើង។ ប៉ុន្តែជាក់ស្តែងនៅក្នុងសង្គមកម្ពុជាយើង ចំនួនតួលេខរបស់ស្ត្រី បំរើការជាសមាជិកសភា មានចំនួន ១៨ ភាគរយ និងមាន តែ ៨.៧ ភាគរយ នៃក្រុមប្រឹក្សាឃុំជាស្ត្រី (៩៨៣ រូបក្នុងចំណោមក្រុមប្រឹក្សាឃុំ ១១,២៦១ រូប) តួលេខនេះបញ្ជាក់ថានៅមានកំរិតទាបនៅឡើយ។ នេះមិនមែនមានន័យថាស្ត្រីមិនចង់ចូលរួមក្នុងការងារសង្គមទេ គឺមានកត្តាច្រើនណាស់ដែលជារនាំង រារាំងធ្វើអោយស្ត្រី មិនមានឱកាសចូលរួមបាន។ ការគោរពសិទ្ធិនារី លើកកំពស់និងផ្តល់ឱកាសអោយស្ត្រីជាអ្នកដឹកនាំ គឺជាកំលាំងដ៏ខ្លាំងក្លាដែលជំរុញអោយស្ត្រីប្រើប្រាស់សិទ្ធិស្របច្បាប់របស់ខ្លួនយ៉ាងមានប្រសិទ្ធិភាពក្នុងការបំរើការងារសង្គម ដែលជះឥទ្ធិពលអោយស្ថានភាព សន្តិសុខស្បៀងក្នុងគ្រួសារប្រសើរឡើង។

សន្តិសុខស្បៀងគឺជាប្រធានបទមួយទាក់ទិន នឹងផែនការយុទ្ធសាស្ត្រទី១នៃយុទ្ធសាស្ត្រចតុកោណអាណត្តិទី៣ ហើយក៏ជាផ្នែកមួយដែលជ្រើសរើសចេញពីគោលដៅអភិវឌ្ឍន៍សហស្សវត្ស៍ ដែលឆ្លើយតបទៅនឹងអនុសញ្ញាស្តីពីលុបបំបាត់រាល់ទំរង់នៃការរើសអើងលើនារីភេទ និងរួមជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ ៥ឆ្នាំបន្ត ២០០៦-២០១០ ក្នុងការកាត់បន្ថយនូវភាពក្រីក្រ ពិសេសតំបន់ជនបទដាច់ស្រយាលដែលមានអង្គការជាតិ-អន្តរជាតិ កំពុងដំណើរការយ៉ាងស្រួចស្រាវផងដែរ។ សន្តិសុខស្បៀងរបស់ប្រជាជននៅតាមតំបន់ជនបទនៅមានកាខ្វះខាត ដោយពុំមានស្រូវអង្ករ និងម្ហូបអារហារគ្រប់គ្រាន់ ក្នុងមួយឆ្នាំពេញ ដែលជា ហេតុនាំ ឱ្យមានការជំពាក់បំណុល និង មានជំងឺ ។ យ៉ាងណាមិញប្រជាជនមានការលំបាកក្នុងការរកទីផ្សារលក់ផលិតផល និង ពុំមាន ការងារធ្វើ ។

ជាថ្មីម្តងទៀតតាងនាមខ្លួនខ្ញុំបាទផ្ទាល់ និងគណៈកម្មការរៀបចំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ ឯកឧត្តម ណាំ ទុំ អភិបាលខេត្តកំពង់ធំ ដែលបានអនុញ្ញាត និងផ្តល់ទីកន្លែងរៀបចំទិវានេះឡើង នឹងជឿជាក់ថាកិច្ចសហការដ៏ជិតស្និតរវាង អង្គការមិនមែនរដ្ឋាភិបាល សង្គមស៊ីវិលនានា ជាមួយដៃគូនៃរាជរដ្ឋាភិបាលនឹងមានដំណើរយ៉ាងរលូនដើម្បីរួមគ្នាកាត់បន្ថយនូវភាពក្រីក្រ។ ជាពិសេសសូមថ្លែងអំណរគុណដល់មន្ទីរកិច្ចការនារី ដែលបានសហការយ៉ាងពេញទំហឹង ដើម្បីអោយទិវាមានដំណើរការប្រកបដោយជោគជ័យ និងសូមអរគុណចំពោះ អង្គការអភិវឌ្ឍន៍ និងភាពជាដៃគូរក្នុងសកម្មភាព (DPA) ដែលចូលរួមផ្តល់ ជាអាវយឺត និង អង្គការ Maryknoll ដែលចូលរួមនូវសកម្មភាពអប់រំផ្សព្វផ្សាយ ដែលញុំាងអោយទិវាកាន់តែប្រព្រឹត្តិទៅយ៉ាងរស់រវើក ហើយក៏សូមថ្លែងអំណរគុណដល់សមាជិកបណ្តាញវេទិកាយេនឌ័រ លោក/លោកស្រីតំណាងអង្គការមិនមែនរដ្ឋាភិបាល លោកគ្រូ/អ្នកគ្រូ ប្អូនៗ សិស្សានុ សិស្ស លោកអ៊ី ពូ មីង បងប្អូនទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតំលៃចូលរួម ក្នុងទិវានេះ នឹងសង្ឃឹមថា អ្នកចូលរួមទាំងអស់នឹងទទួលបាននូវចំណេះដឹងដើម្បីយកទៅប្រើប្រាស់អប់រំផ្សព្វផ្សាយបន្តដើម្បី ជាប្រយោជន៍ដល់សង្គមជាតិទាំងមូល។

នៅចុងបញ្ចប់ខ្ញុំបាទសូមគោរពជូនពរអោយ ទិវាអន្តរជាតិនារី ៨មីនា លើកទី ៩៧ ឆ្នាំ២០០៧ មានដំណើរការប្រកបដោយជោគជ័យ និង សូមគោរពជូនពរ គណៈអធិបតី ឯកឧត្តម លោក-លោកស្រី លោកគ្រូ/អ្នកគ្រូ ប្អូនៗ សិស្សានុ សិស្ស លោកអ៊ី ពូ មីង បងប្អូនទាំងអស់ជួបតែពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិធាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

អបអរសារទរទិវាអន្តរជាតិនារី ៨មីនា លើកទី ៩៧

**សូមអរព្រះគុណ និង អរគុណ**